លេខ៖ ២៨៥/ម.ជ.ម./២៤

# សេចក្តីណែនាំ
## ស្តីពី
## ការស្នើសុំពិន្ទុក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់សមាជិកជាមជ្ឈត្តករ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** (ម.ជ.ម.) បានដាក់ឱ្យអនុវត្តនូវគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈបន្ត ស្របតាមសេចក្តីជូនដំណឹងលេខ ០០៩/ម.ជ.ម./២៤ ស្តីពីការអនុវត្តគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈបន្ត ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។ ផ្អែកតាមសេចក្តីជូនដំណឹងនេះ សមាជិកជាមជ្ឈត្តករ ត្រូវចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីទទួលបានពិន្ទុ CPD យ៉ាងតិច ១០ (ដប់) ម៉ោង ឬស្មើនឹង ១០ (ដប់) ពិន្ទុ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ តាមរយៈការចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលរៀបចំដោយ ម.ជ.ម. ឬស្ថាប័នផ្សេងទៀតដែលទទួលស្គាល់ដោយ ម.ជ.ម. ឬតាមរយៈសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន ដូចមានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់សមាជិកជាមជ្ឈត្តកររបស់ ម.ជ.ម.។

សម្រាប់ការស្នើសុំពិន្ទុក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់សមាជិកជាមជ្ឈត្តករ ម.ជ.ម. សូមធ្វើការណែនាំដល់សមាជិកជាមជ្ឈត្តករឱ្យបំពេញពាក្យស្នើសុំពិន្ទុសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដោយធ្វើការបំពេញទម្រង់ពាក្យសុំតាមរយៈតំណភ្ជាប់ក្នុង QR Code នៃសេចក្តីណែនាំនេះ។ នៅពេលបានទទួលពាក្យសុំពិន្ទុក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់សមាជិកជាមជ្ឈត្តករ អគ្គលេខាធិការដ្ឋានរបស់ម.ជ.ម. នឹងបញ្ជូនពាក្យស្នើសុំនេះទៅកាន់គណៈកម្មាធិការអប់រំ និងបណ្តុះបណ្តាល របស់ ម.ជ.ម. ដើម្បីពិនិត្យ និងផ្តល់ពិន្ទុដល់សមាជិកជាមជ្ឈត្តករសម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត អនុលោមតាមគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ ម.ជ.ម.។

សម្រាប់ព័ត៌មានបន្ថែម អំពីការស្នើសុំពិន្ទុក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់សមាជិកជាមជ្ឈត្តកររបស់ ម.ជ.ម. សូមទំនាក់ទំនងមកអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. តាមរយៈលេខទូរស័ព្ទ៖ (+៨៥៥) ៩៦ ៨៨៨ ៥៣៣៣ ឬតាមរយៈអ៊ីម៉ែល៖ membership@ncac.org.kh នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសមាជិកជាមជ្ឈត្តកររបស់ ម.ជ.ម. ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
*រាជធានីភ្នំពេញ* ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**
**ប្រធាន**

NATIONAL COMMERCIAL ARBITRATION CENTRE

មជ្ឈត្តករ **សាន គីរី**

ស្កេនសម្រាប់ទម្រង់នៃពាក្យស្នើសុំពិន្ទុ CPD សម្រាប់សមាជិកមជ្ឈត្តករ



ជាន់ទី៣៧ អគារ GIA Tower ផ្លូវសុភមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
37th Floor, GIA Tower, Street Sopheak Mongkul, Tonle Bassac, Chamkarmon, Phnom Penh, Cambodia
T: +855 96 888 5333 | E: info@ncac.org.kh | W: www.ncac.org.kh